វិទ្យាស្ថានបើកទូលាយ
Open Institute

# កិច្ចប្រជុំវេទិកាស្ត្រី ដំណាក់កាលទី២ លើកទី៣

# ស្តីពី

# «តម្រូវការបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងបញ្ចប់អំពើហិង្សា លើស្ត្រី»

## ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៨





រៀបចំកម្មវិធីដោយ៖

អំពីស្ត្រី

ឧបត្ថម្ភដោយ៖

OPEN SOCIETY INSTITUTE
& Soros Foundations Network

MINISTERIO DE ASUNTOS EXTERIORES Y DE COOPERACIÓN
aecid

## តារាងមាតិកា


I.ព័ត៌មានទូទៅ............................................................................................................១

II. សេចក្តីផ្តើម ............................................................................................................២

III. គោលបំណងនៃកិច្ចប្រជុំ.............................................................................................២

IV. របៀបវារៈនៃកិច្ចប្រជុំ...............................................................................................២

V.ខ្លឹមសារលំអិតនៃកិច្ចប្រជុំ.............................................................................................៣

១. ចំណាប់អារម្មណ៍ស្វាគមន៍...........................................................................................៣

២. បទឧទ្ទេសនាម អំពី «សកម្មភាព និងសមិទ្ធផល របស់អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍសហស្សវត្សកម្ពុជា ២០១៥ ក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រី» ...........................................................................................................................៤

៣. បទឧទ្ទេសនាម អំពី «សកម្មភាព និងសមិទ្ធផល សមាគមអភិវឌ្ឍន៍សុខភាពប្រជាជន ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍសហស្សវត្សកម្ពុជា២០១៥ ក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រី» .......៥

៤. សង្ខេបខ្លឹមសារនៃកិច្ចប្រជុំវេទិកាស្ត្រី លើកទី១ និងលើកទី២ (ដំណាក់កាលទី២) .....................៧

៥. កិច្ចពិភាក្សា............................................................................................................១០

សំណួរទី៧..............................................................................................................១០

សំណួរទី៨ និងទី៩....................................................................................................១៣

VI. លទ្ធផលនៃកិច្ចពិភាក្សា.............................................................................................១៥

VII. សេចក្តីបញ្ចប់.......................................................................................................១៧

# របាយការណ៍កិច្ចប្រជុំវេទិកាស្ត្រី លើកទី៣

# ស្តីពី

# «តម្រូវការបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី»

**គោលដៅអភិវឌ្ឍន៍សហស្សវត្សរកម្ពុជា[1]៖**

**គោលដៅអភិវឌ្ឍន៍សហស្សវត្សរកម្ពុជា ៣៖ ជំរុញសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី**

- គោលដៅរួម ៨៖ ធ្វើឲ្យមានការកាត់បន្ថយគួរឲ្យកត់សម្គាល់នូវរាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និង កុមារ
- គោលដៅ ៣..១៧៖ បង្កើនភាគរយនៃការយល់ដឹងរបស់ប្រជាជនថា អំពើហិង្សាលើស្ត្រី និងកុមារ គឺជាអាកប្បកិរិយាខុសឆ្គង និងជាបទឧក្រិដ្ឋ ឲ្យបាន១០០% នៅឆ្នាំ២០១៥។

## I. ព័ត៌មានទូទៅ

- កាលបរិច្ឆេទ៖ ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០០៨
- ពេលវេលា៖ ម៉ោង ០៩.០០ ព្រឹក ដល់ ១១.៣០ ថ្ងៃត្រង់
- រយៈពេល៖ ២ ម៉ោង និង ៣០នាទី
- រៀបចំដោយ៖ អង្គការវិទ្យាស្ថានបើកទូលាយ
- ទីកន្លែង៖ អង្គការវិទ្យាស្ថានបើកទូលាយ
- សមាជិកចូលរួមប្រជុំ៖
  - តំណាងស្ថាប័នរដ្ឋាភិបាល
  - តំណាងអង្គការធ្វើការងារអំពីស្ត្រី
  - តំណាងអង្គការសិទ្ធិមនុស្ស
  - តំណាងអង្គការអន្តរជាតិ
  - តំណាងវិទ្យុក្នុងស្រុក
  - សមាជិកគម្រោងកម្មវិធីស្ត្រី នៃអង្គការវិទ្យាស្ថានបើកទូលាយ

១. http://www.mop.gov.kh/Default.aspx?tabid=156

## II. សេចក្តីផ្តើម

កាលពី ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០០៨ កម្មវិធីស្ត្រី នៃអង្គការវិទ្យាស្ថានបើកទូលាយបានរៀបចំកិច្ចប្រជុំវេទិកាស្ត្រី (Women Forum) ដំណាក់កាលទី២ លើកទី៣ ពិភាក្សាលើប្រធានបទ **«តម្រូវការបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី»**។ ចូលរួមក្នុងឱកាសនោះមានតំណាងមកពីក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គណៈកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនារីភេទ(CEDAW) អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ សមាគមអភិវឌ្ឍន៍សុខភាពប្រជាជន អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា អង្គការចំរើនស្ត្រី ការិយាល័យសំរាប់ការសហការរបស់កាណាដា សមាគមនារីអភិវឌ្ឍន៍ អង្គការអភិវឌ្ឍន៍ស្ត្រីកម្ពុជា អង្គការសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ អង្គការសមាគមនារីអភិវឌ្ឍន៍ អង្គការនារីដើម្បីសន្តិភាព អង្គការអ៊ិកផាក-កម្ពុជា អង្គការជំនួយរបស់វិហារដាណឺម៉ាក និងវិទ្យុសម្លេងប្រជាធិបតេយ្យ។

## III. គោលបំណងនៃកិច្ចប្រជុំ

កិច្ចប្រជុំវេទិកាស្ត្រីធ្វើឡើងក្នុងគោលបំណង៖




១. ស្វែងយល់ និងវិភាគអំពីប្រភពនៃបញ្ហាការរើសអើង និងទំនាក់ទំនងរវាងហេតុ និងផល
២. ធ្វើការវិភាគ ស្វែងរកយុទ្ធសាស្ត្រ និងការតស៊ូមតិសមស្របសម្រាប់ដំណោះស្រាយជារួម
៣. បញ្ជ្រាបការយល់ដឹងអំពីសិទ្ធិ ដើម្បីឈានទៅរកការលុបបំបាត់នូវការរើសអើង បង្កើនសមត្ថភាពចាំបាច់ និងសមត្ថភាពក្នុងភាពជាអ្នកដឹកនាំសម្រាប់ស្ត្រី

## IV. របៀបវារៈនៃកិច្ចប្រជុំ

១. ចំណាប់អារម្មណ៍ស្វាគមន៍ដោយ **លោកស្រី ជឹម ម៉ាណាវី** នាយិកាប្រតិបត្តិ នៃអង្គការវិទ្យាស្ថានបើកទូលាយ
២. បទឧទ្ទេសនាម អំពី «**សកម្មភាព និងសមិទ្ធផល របស់អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍសហស្សវត្សកម្ពុជា ២០១៥ ក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រី**» ដោយលោកស្រី **ច័ន្ទ សារ៉េត** អ្នកសម្របសម្រួលកម្មវិធីផ្សព្វផ្សាយជាសាធារណៈ នៃអង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ
៣. បទឧទ្ទេសនាម អំពី «**សកម្មភាព និងសមិទ្ធផល សមាគមអភិវឌ្ឍន៍សុខភាព ប្រជាជនឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍសហស្សវត្សកម្ពុជា២០១៥ ក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រី**» ដោយលោក **អ៊ូ រតនៈ** នាយកប្រតិបត្តិ នៃសមាគមអភិវឌ្ឍន៍សុខភាពប្រជាជន
៤. សង្ខេបខ្លឹមសារនៃកិច្ចប្រជុំវេទិកាស្ត្រីលើកទី១ និងលើកទី២(ដំណាក់កាលទី២) ដោយ **កញ្ញា ប្រាក់ សុខាយុ** អ្នកសម្របសម្រួលគម្រោងកម្មវិធីស្ត្រី នៃអង្គការវិទ្យាស្ថានបើកទូលាយ

៥. កិច្ចពិភាក្សា

## V. ខ្លឹមសារលំអិតនៃកិច្ចប្រជុំ

### *១. ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោកស្រី ជឹម ម៉ាណាវី នាយិកាប្រតិបត្តិ នៃអង្គការវិទ្យាស្ថានបើកទូលាយ*


*លោកស្រី ជឹម ម៉ាណាវី នាយិកាប្រតិបត្តិ អង្គការវិទ្យាស្ថានបើកទូលាយ*

ជាកិច្ចចាប់ផ្តើម លោកស្រី ជឹម ម៉ាណាវី នាយិកាប្រតិបត្តិនៃអង្គការវិទ្យាស្ថានបើកទូលាយ បានមានប្រសាសន៍ថ្លែងអំណរគុណចំពោះការអញ្ជើញចូលរួមរបស់លោក លោកស្រីដែលជាតំណាងស្ថាប័នរដ្ឋាភិបាល អង្គការស្ត្រី និងភ្នាក់ងារសារព័ត៌មាន ។ លោកស្រីនាយិកាបានមានប្រសាសន៍ថា កិច្ចប្រជុំវេទិកាស្ត្រីធ្វើឡើងក្នុងគោលបំណងស្វែងយល់ និងវិភាគអំពីប្រភពនៃបញ្ហា និងស្វែងរកយុទ្ធសាស្ត្រសមស្របសម្រាប់ដំណោះស្រាយជារួម ព្រមទាំងបញ្ជ្រាបការយល់ដឹងអំពីសិទ្ធិ បង្កើនសមត្ថភាពក្នុងភាពជាអ្នកដឹកនាំសម្រាប់ស្ត្រី ។ លោកស្រីបានបន្តថា កិច្ចប្រជុំវេទិកាស្ត្រីមានការកំណត់ការអញ្ជើញអ្នកចូលរួមត្រឹមតែចំនួនពី១៥ ទៅ២៥នាក់ប៉ុណ្ណោះ ដោយជ្រើសរើសយកអ្នកដែលមានជំនាញពាក់ព័ន្ធដូចជា បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ស្ត្រី យេនឌ័រ ការនិពន្ធ សិក្សាស្រាវជ្រាវ និងច្បាប់ជាដើម។ អ្នកដែលបានអញ្ជើញចូលរួមគឺសុទ្ធតែត្រូវបានជ្រើសរើស ដើម្បីធ្វើឲ្យកិច្ចប្រជុំនេះមានការពិភាក្សាពិតៗអំពីបញ្ហាស្ត្រី ។ លោកស្រីមានប្រសាសន៍ថា កិច្ចប្រជុំវេទិកាស្ត្រីលើកនេះ នឹងត្រូវពិភាក្សាទៅលើប្រធានបទ «**តម្រូវការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី**» ។

នៅក្នុងឱកាសនេះ លោកស្រីមានប្រសាសន៍ថា អំពើហិង្សាមានច្រើនប្រភេទ រួមមានអំពើហិង្សាលើរូបរាងកាយ លើផ្លូវចិត្ត ផ្លូវសេដ្ឋកិច្ច ។ល។ កាលពីឆ្នាំ១៩៩៣ មហាសន្និបាតអង្គការសហប្រជាជាតិ បានដាក់ចេញនូវនិយមន័យនៃពាក្យអំពើហិង្សាលើស្ត្រី។ នៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី ដែលត្រូវបានមហាសន្និបាតអនុមតិ (General Assembly resolution 48/104 of 20 December 1993[២]) ហើយត្រូវបានគេប្រើប្រាស់ទូលំទូលាយនោះ មាត្រាមួយបានចែងថា "**អំពើហិង្សាលើស្ត្រី**" មានន័យថា អំពើហិង្សាទាក់ទងយេនឌ័រទាំងឡាយណា ដែលនឹងនាំឲ្យមានគ្រោះអន្តរាយ ឬការឈឺចាប់ផ្លូវរាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត ដោយរួមមានការគំរាមកំហែង បង្ខិតបង្ខំ ឬរំលោភបំពានសេរីភាព ដែលអំពើទាំងនោះកើតឡើងនៅទី សាធារណៈ ឬជីវិតឯកជន។

លោកស្រីមានប្រសាសន៍បន្តថា តាមរយៈឯកសាររបស់អង្គការអន្តរជាតិ GTZ ស្តីពីការបញ្ចប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ក្នុងគោលបំណងការពារសិទ្ធិមនុស្ស ដោយបានបង្ហាញអំពីស្ថានភាពទូទៅនៃអំពើហិង្សាលើស្ត្រីនោះបានបង្ហាញថា អំពើហិង្សាលើស្ត្រីមានការរីករាលដាលគួរឲ្យភ្ញាក់ផ្អើល។ ឯកសារបន្តថា គេប៉ាន់ប្រមាណជាទូទៅថា ក្នុងចំណោមស្ត្រី ៣នាក់នៅទូទាំងពិភពលោក មានម្នាក់នឹងត្រូវទទួលរងនូវការឈឺចាប់ដោយអំពើហិង្សាទាក់ទងយេនឌ័រនៅក្នុងជីវិតរស់នៅរបស់ពួកគេ។ អំពើទាំងនោះ រួមមានការវាយដំ

២. http://www.unhchr.ch/huridocda/huridoca.nsf/(Symbol)/A.RES.48.104.En

រំលោភ ការវាយប្រហារ ការត្រូវគេជួញដូរ ត្រូវគេសម្លាប់ ការប្រមាថ ការដាក់កំហិតក្នុងការដើរហើរ និងទំនាក់ទំនងសង្គម។ល។ (UN Commission on the status of women 28/2/00)[៣]។ អំពើហិង្សាលើស្ត្រីបានធ្វើឲ្យអន្តរាយដល់សមភាពយេនឌ័រ។ អំពើហិង្សាលើស្ត្រី គឺជាលទ្ធផលដែលអាចមើលឃើញច្បាស់អំពីអសមភាពយេនឌ័រ និងការខ្វះអំណាចរបស់ស្ត្រី។ ដូច្នេះហើយ យើងមិនអាចសម្រេចបានគោលដៅអភិវឌ្ឍសហស្សវត្សឡើយ ប្រសិនបើអំពើរំលោភបំពាននេះនៅតែកើតមាន (Ending Violence against Women and Girls-Protecting Human Rights, GTZ)។

លោកស្រីបន្តទៀតថា លោកស្រីបានបន្តថា តាមរយៈ គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជាគោលដៅលេខ III ស្តីពីការជំរុញសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រីក្នុងគោលដៅរួម៨ ចែងថា *នឹងធ្វើឲ្យមានការកាត់បន្ថយគួរឲ្យកត់សម្គាល់នូវរាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និង កុមារ* និងគោលដៅ ៣.១៧ *ប្រទេសកម្ពុជានឹងបង្កើនភាគរយនៃការយល់ដឹងរបស់ប្រជាជនថា អំពើហិង្សាលើស្ត្រី និងកុមារគឺជាអាកប្បកិរិយាខុសឆ្គង និងជាបទឧក្រិដ្ឋឲ្យបាន១០០% នៅឆ្នាំ២០១៥*[៤]។

## *២. បទឧទ្ទេសនាម អំពី «សកម្មភាព និងសមិទ្ធផល របស់អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍសហស្សវត្សកម្ពុជា ២០១៥ ក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រី» ដោយលោកស្រី ច័ន្ទ សារ៉េត អ្នកសម្របសម្រួលកម្មវិធីផ្សព្វផ្សាយជាសាធារណៈ នៃអង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ*



*លោកស្រី ច័ន្ទ សារ៉េត*
*អ្នកសម្របសម្រួលកម្មវិធីផ្សព្វផ្សាយជាសាធារណៈ នៃអង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ*

លោកស្រី ច័ន្ទ សារ៉េត មានប្រសាសន៍ថ្លែងអំណរគុណ អង្គការវិទ្យាស្ថានបើកទូលាយដែលបានអញ្ជើញលោកស្រីចូលរួមផ្តល់បទឧទ្ទេសនាមអំពីសកម្មភាពរបស់អង្គការប្រឆាំងអំពើហិង្សាលើស្ត្រី នៅក្នុងកិច្ចប្រជុំវេទិកាស្ត្រីនាឱកាសនេះ។ លោកស្រីមានប្រសាសន៍ថា អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៥ បន្ទាប់ពីមានការស្រាវជ្រាវមួយនៅក្នុងឆ្នាំ១៩៩៤។ ការស្រាវជ្រាវនេះមានឈ្មោះថា «ឋានក្នុងរវាំងតែងរណ្តំ»។ នៅក្នុងការស្រាវជ្រាវនេះបានរកឃើញថា មានស្ត្រីចំនួន១៦% ទទួលរងនូវការប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ។ លោកស្រីមានប្រសាសន៍ថា អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារមានទស្សនវិស័យ ចង់មានសង្គមមួយ ដែលមនុស្សគ្រប់គ្នាជៀសផុតអំពីអំពើហិង្សាក្នុងគ្រួសារ។ ចំណែកឯបេសកកម្មរបស់អង្គការលោកស្រីគឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ធ្វើការដើម្បីកាត់បន្ថយ និងលុបបំបាត់នូវអំពើហិង្សាក្នុងគ្រួសារ និងជួយសង្គ្រោះជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ។ លោកស្រីបានបន្តថា អង្គការលោកស្រីមានកិច្ចសហការជាមួយស្ថាប័ន និងអង្គការមួយចំនួន ដូចជា៖ ក្រសួងកិច្ចការនារី ក្រសួងអប់រំ ក្រសួងមហាផ្ទៃ សាលាក្រុងភ្នំពេញ អាជ្ញាធរតាមបណ្តាខេត្តក្រុង និងដៃគូរអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការទាក់ទងនឹងបញ្ហាស្ត្រី។ អង្គការលោកស្រីមានក្រុមគោលដៅ ដូចជា ក្រសួងកិច្ចការនារី ប៉ូលិស អាជ្ញាធរមូលដ្ឋាន ប្រជាជនរស់នៅក្នុងសហគមន៍ និងសិស្សនិស្សិត។

លោកស្រីមានប្រសាសន៍ថា អង្គការលោកស្ត្រីមានកម្មវិធីស្ត្រីមួយចំនួនដូចជា៖

១. **កម្មវិធីទូទៅ៖** មានសកម្មភាពមួយចំនួនដូចជា ការបញ្ចុះបញ្ចូល និងការតស៊ូមតិ ការសហការជា

---

៣. http://www.peacewomen.org/un/ecosoc/CSW/CSWindex.html

៤ http://www.mop.gov.kh/Default.aspx?tabid=156

មួយស្ថាប័ន និងអង្គការផ្សេងៗ ការពង្រឹងសមត្ថភាព ការតាមដាន និងការវាយតម្លៃ។

២. **កម្មវិធីអប់រំ៖** មានគោលបំណងលើកកម្ពស់ការយល់ដឹង និងការអប់រំអំពីអំពើហិង្សាក្នុងគ្រួសារ ដល់ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ និងបុគ្គលិកនៃអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ

៣. **កម្មវិធីផ្តល់ព័ត៌មានសមស្រប៖** គឺជាកម្មវិធីដែលផ្តល់ជូននូវព័ត៌មាន និងការគាំទ្រដោយផ្ទាល់ដល់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ ដែលបានមកការិយាល័យរបស់អង្គការលោកស្រី ក៏ដូចជាជនរងគ្រោះដែលទទួលរងពីអំពើនេះនៅតាមតំបន់គោលដៅ។

៤. **កម្មវិធីផ្សព្វផ្សាយជាសាធារណៈ ៖** គឺជាការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដោយមានផលិតជាស្ពតខ្លីៗស្តីអំពីអំពើហិង្សាក្នុងគ្រួសារ។ ក្រៅពីនោះ អង្គការលោកស្រីក៏មានផលិតជាសម្ភារៈផ្សព្វផ្សាយ ដូចជា ខិត្តប័ណ្ណ និងអាវយឺតដែលមានសារសម្រាប់ផ្សព្វផ្សាយ។

៥. **កម្មវិធីបញ្ឈប់កំហឹងបុរស៖** ជាជំហានដំបូង កម្មវិធីនេះធ្វើផ្ទាល់ជាមួយបុរស និងយុវជនដែលប្រើអំពើហិង្សា ដោយមានការជួបប្រជុំគ្នា និងពិភាក្សាអំពីមូលហេតុដែលធ្វើឲ្យពួកគាត់ប្រើអំពើហិង្សា។ នៅឆ្នាំ២០០៥ អង្គការលោកស្រីបានចាប់យកស្ត្រី និងបុរស ជាក្រុមគោលដៅសម្រាប់កម្មវិធី។

៦. **កម្មវិធីប្រឆាំងការជួញដូរកុមារ**

## *៣. បទឧទ្ទេសនាម អំពី «សកម្មភាព និងសមិទ្ធផល សមាគមអភិវឌ្ឍន៍សុខភាពប្រជាជន ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍសហស្សវត្សរកម្ពុជា២០១៥ ក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រី» ដោយលោក អ៊ូ រតនៈ នាយកប្រតិបត្តិ នៃសមាគមអភិវឌ្ឍន៍សុខភាពប្រជាជន*



*លោក អ៊ូ រតនៈ នាយកប្រតិបត្តិ សមាគមអភិវឌ្ឍន៍សុខភាពប្រជាជន*

លោក អ៊ូ រតនៈ បានលើកឡើងថា សមាគមសុខភាពប្រជាជន បង្កើតឡើងក្នុងឆ្នាំ២០០៥ និងមានក្រុមគោលដៅជានិស្សិតនៅតាមសកលវិទ្យាល័យ ដែលតាមការសង្កេតឃើញ លោកយល់ថា យើងនៅមានចន្លោះប្រហោង ដោយមើលរំលងក្រុមនិស្សិតនៅតាមតាមសកលវិទ្យាល័យ សម្រាប់ការបង្ការ ឬការចូលរួមណាមួយរបស់ពួកគាត់ក្នុងនាមជាយុវវ័យ។ លោកបានបន្តថា សមាគមលោកបានបង្កើតគម្រោងមួយឈ្មោះថា **គំនិតផ្តួចផ្តើមសុខភាពយុវវ័យ** ដែលមានគោលបំណងសំខាន់ធ្វើយ៉ាងណាឲ្យមានចំណេះដឹង និងមានបំឡាស់ប្តូរឥរិយាបថរបស់ពួកគាត់ក្នុងការឆ្លើយតបទៅនឹងការបង្ការបញ្ហាជំងឺអេដស៍ សុខភាពបន្តពូជ ដែលបញ្ហាទាំងអស់នេះផ្សារភ្ជាប់ទៅនឹងភាពជាបុរស និងការលំអៀងផ្នែកយេនឌ័រ ដែលក្នុងនោះរួមមានការប្រើអំពើហិង្សាផងដែរ។ គម្រោងនេះកើតឡើង តាមរយៈការធ្វើការស្រាវជ្រាវមួយបានឲ្យឃើញថា អំពើហិង្សាសំដៅទៅលើហិង្សាទាំងឡាយណា ដែលធ្វើឲ្យប៉ះពាល់ដល់រាងកាយ ផ្លូវចិត្ត ផ្លូវអារម្មណ៍ ផ្លូវភេទ និងផ្លូវសេដ្ឋកិច្ច។ លោកបានបន្តថា តាមការស្រាវជ្រាវបានបង្ហាញថា និស្សិតស្ត្រី និងស្ត្រីដែលជាអ្នកបម្រើសេវាកម្មកម្សាន្ត មានសិទ្ធិតិចតួចបំផុតក្នុងការចរចាជាមួយអតិថិជន ឬបុរសដែលជាដៃគូរសម្រាប់បញ្ហាការរួមភេទ។ លោកបានបន្តថា ស្ត្រីក៏ជាជនដែលរងគ្រោះនៅកន្លែងធ្វើការ ដោយសារតែទទួលរងនូវការបៀតបៀន។ សមាគមរបស់លោកធ្វើការជាមួយយុវវ័យក្នុងគោលបំណងបង្ហាញឲ្យពួកគាត់យល់ឃើញថា អ្វីដែលគួរធ្វើ និងស្របច្បាប់ ដែល

ផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅរបស់ពួកគាត់។ គម្រោងកម្មវិធីរបស់សមាគមលោក មានក្រុមគោលដៅជាយុវជន ដែលក្នុងនោះមានបុរសចំនួន៧០% ដែលពួកគាត់ជាអ្នកដែលបង្កឲ្យមានបញ្ហាកើតឡើង និងស្ត្រីចំនួន៣០% ដែលជាជនរងគ្រោះ។ លោកបានទទួលស្គាល់ថា អំពើហិង្សាភាគច្រើន គឺកើតឡើងពីបុរស និងភាពជាបុរស។ វប្បធម៌របស់សង្គមធ្វើឲ្យមានភាពលំអៀង ដូចជា ចាប់តាំងពីចាប់កំណើត កូនប្រុសត្រូវបានចាត់ទុកដូចជាគ្រាប់ពេជ្រ និងអ្វីដែលគាត់ធ្វើគឺត្រូវទាំងអស់។ គម្រោងកម្មវិធីរបស់សមាគមលោកនឹងធ្វើឲ្យមានការប្រែប្រួលឥរិយាបថ និងចេះប្រើប្រាស់នូវភាពជាបុរសរបស់គាត់ឲ្យមានភាពវិជ្ជមាន និងមានភាពប្រសើរឡើងនៅក្នុងការបង្ការ និងការពារជនរងគ្រោះ ដែលអាចជាម្តាយ បងប្អូនស្រី និងសាច់ញាតិរបស់គាត់ និងធ្វើឲ្យពួកគាត់មានការទទួលខុសត្រូវក្នុងការបង្ការ និងទប់ស្កាត់ចំពោះការប្រើប្រាស់អំពីហិង្សាលើស្ត្រី។

នាពេលថ្មីៗនេះ សមាគមសុខភាពប្រជាជន ក្រោមកិច្ចសហការជាមួយអង្គការយូនីហ្វេមប្រចាំប្រទេសកម្ពុជា និងអង្គការវិទ្យាស្ថានបើកទូលាយ បានចូលរួមក្នុងយុទ្ធនាការពិភពលោកមួយ ស្តីពី «**ការនិយាយថា ទេ ចំពោះអំពើហិង្សាលើស្ត្រី**» និងក្នុងឱកាសនៃទិវាយុវជនអន្តរជាតិ លោកបានរៀបចំជាយុទ្ធនាការមួយស្តីពី «**យុវជននិយាយថា ទេ ចំពោះអំពើហិង្សាលើស្ត្រី**»។ ក្នុងយុទ្ធនាការទាំងពីរនេះ សមាគមលោកមានគោលបំណងធ្វើឲ្យស្ថាប័នដែលពាក់ព័ន្ធ និងយុវជនយល់ថាអំពើហិង្សាមិនមែនជារឿងរបស់បុគ្គលតែម្នាក់ទេ តែវាជារឿងសកល និងពួកគាត់យល់ថាអំពើហិង្សាបង្កឲ្យមានផលប៉ះពាល់ជាច្រើន និងធ្វើឲ្យពួកគាត់យល់ថាអំពើហិង្សាមិនមែនជារឿងធម្មតា និងមិនត្រូវធ្វើព្រងើយកន្តើយចំពោះអំពើហិង្សានោះទេ។ នៅក្នុងយុទ្ធនាការនេះ សមាគមលោកប្រមូលបានហត្ថលេខាចំនួន**៣៨៥១** និងបានបញ្ជូនមកដល់អង្គការវិទ្យាស្ថានបើកទូលាយសម្រាប់បញ្ចូលលើវិបផតថលស្តីអំពីស្ត្រី http://women.open.org.kh។ ហត្ថលេខាទាំងនេះបានមកពីការប្រមូលតាមសកលវិទ្យាល័យទាំង១២ ដែលជាដៃគូសហការជាមួយសមាគមរបស់លោកនៅទីក្រុងភ្នំពេញ និងបានមកពីយុវជននៅតាមតំបន់គោលដៅ។ លោកបានបន្ថែមថា លទ្ធផលនៃយុទ្ធនាការនេះនឹងត្រូវយកទៅធ្វើជាសិនិទ្ទកាសែត ដោយអង្គការយូនីហ្វេមប្រចាំប្រទេសកម្ពុជា នាថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០០៨។

លោកបានបន្ថែមថា ថ្មីៗនេះប្រទេសកម្ពុជាទទួលបានកេរ្តិ៍ឈ្មោះជាប្រទេសឈានមុនគេផ្នែកបង្ការ និងទប់ស្កាត់ការឆ្លងជំងឺអេដស៍ ដូច្នេះប្រទេសកម្ពុជាក៏អាចជាប្រទេសដែលឈានមុខគេក្នុងការទប់ស្កាត់ការប្រើអំពើហិង្សាលើស្ត្រីដែរ។

លោកបានបន្ថែមថា ការលុបបំបាត់អំពើហិង្សាលើស្ត្រី មិនមែនគ្រាន់តែជាសកម្មភាពចូលរួមនៅក្នុងសិទ្ធិមនុស្សនោះទេ តែក៏បានចូលរួមនៅក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស ពីព្រោះនៅពេលណាដែលយើងគ្មានការរើសអើងចំពោះស្ត្រី និងផ្តល់ឱកាស និងសិទ្ធិដល់ស្ត្រីនៅក្នុងការទទួលបានការអប់រំ ការចូលរួមនៅក្នុងសង្គម ការចូលរួមក្នុងវិស័យសាធារណៈ និងឯកជន នោះមានន័យថាយើងបានបង្កើតឲ្យមានការកើនឡើងនូវចំណូលនៅក្នុងគ្រួសារជាលក្ខណៈបុគ្គល និងប្រទេសជាតិ។ នៅក្នុងន័យនេះមានន័យថាមិនមែនមានតែបុគ្គលម្នាក់ទេដែលជាអ្នករកចំណូលសម្រាប់គ្រួសារ គឺមានប្តី និងប្រពន្ធដែលជាដៃគូរក្នុងការរកចំណូលចិញ្ចឹមគ្រួសារ។

លោកស្រីនាយិកា នៃអង្គការវិទ្យាស្ថានបើកទូលាយមានប្រសាសន៍ថា ស្ត្រីកម្ពុជាមានជាង៥២% នៃប្រជាជនសរុប រីឯកម្លាំងស្ត្រីចូលរួមនៅក្នុងកម្លាំងពលកម្មមានចំនួនជាង៧០% នៃកម្លាំងពលកម្មសរុប ដូច្នេះប្រសិនយើងព្រងើយកន្តើយ រើសអើងមនុស្សស្ត្រី ឬមានផ្នត់គំនិតយេនឌ័រ (Gender stereotype) មានន័យថាយើងបានកាត់ចេញនូវកម្លាំងពលកម្មជាងពាក់កណ្តាល។ ក្នុងការអភិវឌ្ឍន៍ប្រទេស ប្រទេសមួយមិនអាចចាត់ទុកថាមានលក្ខណៈប្រជាធិបតេយ្យ បានឡើយប្រសិនបើពុំមានការចូលរួមពីស្ត្រីទេនោះ ពីព្រោះមានតែសម្លេងរបស់បុរសចូលរួមនៅក្នុងអភិវឌ្ឍន៍ ដែលមានចំនួនមិនបានពាក់កណ្តាល និងមិនមានសម្លេងរបស់

មនុស្សគ្រប់រូបនៅក្នុងសង្គមចូលរួមឡើយ។ ដូច្នេះ ការចូលរួមនៅក្នុងការកាត់បន្ថយអំពើហិង្សា និងការរើសអើង គឺជាការបង្ហាញនូវការចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សង្គម និងលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា។

## *៤. សង្ខេបខ្លឹមសារនៃកិច្ចប្រជុំវេទិកាស្ត្រី លើកទី១ និងលើកទី២ (ដំណាក់កាលទី២) ដោយ កញ្ញា ប្រាក់ សុខាយុ អ្នកសម្របសម្រួលគម្រោងកម្មវិធីស្ត្រី នៃអង្គការវិទ្យាស្ថានបើកទូលាយ*



*កញ្ញា ប្រាក់ សុខាយុ អ្នកសម្របសម្រួលគម្រោងកម្មវិធីស្ត្រី នៃអង្គការវិទ្យាស្ថានបើកទូលាយ*

កញ្ញា ប្រាក់ សុខាយុ បានសង្ខេបនូវខ្លឹមសារនៃកិច្ចប្រជុំវេទិកាស្ត្រី ដំណាក់កាលទី២ លើកទី១ និងលើកទី២ ស្តីអំពី «**តម្រូវការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី**» ជូនដល់អង្គប្រជុំ។ កញ្ញាបានលើកឡើងថា នៅរាល់កិច្ចប្រជុំនៃវេទិកាស្ត្រី តែងតែមានការអញ្ជើញពីសំណាក់វាគ្មិន ដើម្បីចូលរួមចែករំលែកនូវបទពិសោធន៍ដែលទាក់ទងនឹងប្រធានបទនៃកិច្ចប្រជុំវេទិកាស្ត្រីម្តងៗ។ ក្នុងកិច្ចប្រជុំវេទិកាស្ត្រី ស្តីពី «**តម្រូវការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី**» ទាំងពីរលើកមានការអញ្ជើញចូលរួមពីសំណាក់លោកជំទាវ **ជូ ប៊ុនអេង** អគ្គនាយក នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម នៃក្រសួងកិច្ចការនារី លោកស្រី **ជីម ចាន់នាង** អ្នកតស៊ូមតិជាន់ខ្ពស់ផ្នែកសិទ្ធិស្ត្រី អង្គការសិទ្ធិមនុស្សលីកាដូ **លោកស្រី នុព្វ សារិនស្រីរត្ន័** អគ្គលេខាធិការ នៃអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ និង**កញ្ញា អ៊ុង ច័ន្ទសោភា** អ្នកយកព័ត៌មាន នៃសារព័ត៌មានកំបូដស័រ។ បន្ទាប់មក កញ្ញាបានលើកបង្ហាញនូវការរកឃើញ និងអនុសាសន៍ដែលកិច្ចប្រជុំវេទិកាស្ត្រីបានពិភាក្សាកន្លងមក៖

- **ការរកឃើញ៖**
  - អំពើហិង្សាមានការកើនឡើងក្នុងរូបភាពកាន់តែឃោរឃៅជាងមុន តាមច្រើនរូបភាព និងកើតឡើងស្ទើរតែលើមនុស្សគ្រប់ៗគ្នា ដែលកម្រនឹងត្រូវបានលាតត្រដាងណាស់
  - អំពើហិង្សាលើស្ត្រីបានបង្កឲ្យមាននូវផលវិបាកមួយចំនួនដូចជា ប៉ះពាល់ដល់សតិបញ្ញាជនរងគ្រោះ សុខភាពស្ត្រី ជីវភាពគ្រួសារ ការរស់នៅរបស់មនុស្សជំនាន់ក្រោយ ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច
  - មានការប៉ាន់ប្រមាណទុកមុនថា នៅក្នុងរយៈពេល ១០ ទៅ ២០ឆ្នាំខាងមុខ ប្រតិកម្មតបតនឹងកើតមានខ្លាំង ជាពិសេសនៅពេលច្បាប់នេះត្រូវបានអនុម័ត និងមានការផ្សព្វផ្សាយអំពីច្បាប់នេះ
  - នៅក្នុងការអនុវត្ត អង្គការសង្គមស៊ីវិលជួបប្រទះនូវការលំបាកមួយចំនួនដូចជា៖ ជំនឿទូទៅរបស់ប្រជាពលរដ្ឋខ្មែរ អំពើពុករលួយ កង្វះភាពសហការពីអាជ្ញាធរ ប៉ូលិស និងតុលាការ និងភាពក្រីក្រ
  - ទស្សនៈរបស់សង្គមខ្មែរដែលតែងតែអោយតម្លៃទៅលើបុរសខ្ពស់ជាងស្ត្រី បញ្ហាសង្គម បញ្ហាអប់រំ ភាពក្រីក្រ និងទំនៀមទម្លាប់ប្រពៃណីមួយចំនួនបានគាបសង្កត់រារាំងស្ត្រីមិនអោយទទួលសិទ្ធិបានពេញលេញ
  - តាមរយៈអ៊ីមែល ឬវិបសាយ អាចធ្វើឲ្យយើងអាចរាយការណ៍ព័ត៌មានដោយមិនចាំបាច់ធ្វើ

ដំណើរទៅកាន់ការិយាល័យប៉ូលិស និងអាចរក្សាការសម្ងាត់។ លោកជំទាវ ជូ ប៊ុនអេង មានជំនឿយ៉ាងមុតមាំថា ក្រសួងមហាផ្ទៃ នាពេលខាងមុខនេះ នឹងប្រើប្រាស់នូវបច្ចេកវិទ្យានេះ

- សមិទ្ធផលការងារដែលក្រសួងកិច្ចការនារីបានធ្វើឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ឆ្នាំ២០១៥ គឺ៖
    - បង្កើតច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលត្រូវបានអនុម័ត និងដាក់ឲ្យប្រើប្រាស់ទូទាំងប្រទេសកម្ពុជា តាំងពីចុងឆ្នាំ២០០៥
    - បង្កើតច្បាប់បង្ក្រាបការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារដែលត្រូវបានអនុម័ត និងដាក់ឲ្យប្រើប្រាស់តាំងពីដើមឆ្នាំ ២០០៨
    - បានព្រាងផែនការជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីជារួម ដោយមានចូលរួមពីក្រសួងចំនួនជាង១០ ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិមួយចំនួន
    - ធ្វើការផ្សព្វផ្សាយទូលាយលើសារសំខាន់ៗមួយចំនួនទាក់ទងអំពើហិង្សាលើស្ត្រីតាមគ្រប់មធ្យោបាយ
- អំពើហិង្សាលើស្ត្រីត្រូវបានធ្វើស្ទើរតែគ្រប់ស្ថាប័ន ប៉ុន្តែនៅពេលក្រសួងស្នើ ឲ្យស្ថាប័នទាំងនោះដាក់សកម្មភាពចូលទៅក្នុងផែនការជាតិ ពុំមានស្ថាប័នណាស្ម័គ្រចិត្តនោះទេ
- រហូតមកដល់ឥឡូវនេះ នៅមិនទាន់មានការស្រាវជ្រាវថ្នាក់ជាតិណាមួយបង្ហាញអំពីអំពើហិង្សាលើស្ត្រីនៅឡើយទេ(មានតែតាមស្ថាប័ននិងអង្គការផ្សេងៗដែលធ្វើដាច់ដោយឡែកពីគ្នា ខ្វះលក្ខណៈប្រមូលផ្តុំព័ត៌មាន)
- រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលគួរធ្វើការរួមគ្នានៅក្នុងខ្លឹមសារ និងផែនការងារ (frame-work)តែមួយ ជៀសវាងការផ្សព្វផ្សាយនូវសារខុសៗគ្នា
- ក្រសួង និងស្ថាប័នធ្វើការអំពីស្ត្រីសុទ្ធសឹងបានប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រី ដូចជាការផ្សព្វផ្សាយតាមអ៊ីនធឺណិត ការផ្តល់លេខទូរស័ព្ទរបស់ប៉ូលិសដល់អ្នកភូមិសម្រាប់ប្តឹងពេលមានអំពើហិង្សាកើតឡើង ការផ្សព្វផ្សាយតាមវិទ្យុ ការផ្សព្វផ្សាយតាមទូរទស្សន៍ ការបោះពុម្ព និងចែកខិតប័ណ្ណផ្សេងៗ។ល។
- បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាបានបង្កនូវភាពងាយស្រួលក្នុងការស្វែងរកឯកសារផ្សេងៗជាច្រើន ដែលមានសារៈសំខាន់ក្នុងការសរសេរគម្រោងផែនការ ឬសម្រាប់ការងារផ្សេងៗ។
- បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាមានសារសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីប្រទេសកម្ពុជាដល់ប្រជាជនកម្ពុជាក៏ដូចជាសម្រាប់ប្រទេសផ្សេងៗស្វែងយល់អំពីប្រទេសកម្ពុជា
- ការផ្សព្វផ្សាយព័ត៌មាន បានធ្វើមានការតាមឃ្លាំមើលពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិធ្វើអោយមានការកែប្រែ ឬបង្កើតបាននូវវិធានការ ឬយន្តការផ្សេងៗ ដើម្បីទប់ស្កាត់ នូវអំពើហិង្សាលើស្ត្រី និងកុមារឈានទៅរកការកាត់បន្ថយនូវសកម្មភាពមិនប្រក្រតី ឬការរំលោភបំពានផ្សេងៗ។
- តែផ្ទុយទៅវិញការផ្តល់ព័ត៌មានមិនពិត មិនត្រឹមត្រូវ និងមិនមានវិជ្ជាជីវៈ គឺជាគ្រោះថ្នាក់មួយសម្រាប់ខ្លួនយើងសម្រាប់សង្គម ធ្វើអោយអ្នកវិភាគមានការវិភាគខុស យល់ខុសទៅលើអ្វីមួយមិនមែនជាការពិត នាំអោយមានការបំពុលនូវបរិយាកាសផ្សេងៗក្នុងសង្គម

- បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ពិតជាមានសារៈសំខាន់ណាស់ ជាពិសេសសម្រាប់អ្នកយកព័ត៌មាន។ តាមរយៈព័ត៌មានដែលមាននៅលើវិបសាយ និងកំណត់ហេតុបណ្តាញ បានធ្វើឲ្យការប្រមូលព័ត៌មានរបស់អ្នកយកព័ត៌មាន កាន់តែសម្បូរបែប ជាជាងការផ្អែកទៅលើការសម្ភាសន៍តែមួយមុខគត់។
- គេអាចប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងការផ្តល់អំណាចដល់ស្ត្រី ធ្វើការចងបណ្តាញពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ពីសហគមន៍មួយទៅសហគមន៍មួយ ដើម្បីកាត់បន្ថយផ្នត់គំនិតយេនឌ័រ ( Gender stereotype)
- រដ្ឋាភិបាលបានបង្កើតឲ្យមាននូវក្រុមយេនឌ័រនៅតាមគ្រប់ក្រសួង ដើម្បីឲ្យមានការយល់ដឹងអំពីច្បាប់ស៊ីដ និងមានធ្វើការតាមដាន និងវាយតម្លៃនូវកម្រិតនៃការយល់ដឹងអំពីច្បាប់ស៊ីដ បន្ទាប់ពីការផ្សព្វផ្សាយ
- បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ពិតជាមានសារៈសំខាន់ណាស់ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី តែវាអាស្រ័យវិធីសាស្ត្រ និងរបៀបនៃការផ្សព្វផ្សាយ។
- ចំណុចខ្សោយនៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យានោះគឺ ស្ត្រីដែលជាភេទទន់ខ្សោយ និងសហគមន៍ក្រីក្រ គឺមិនមានលទ្ធភាពក្នុងការប្រើប្រាស់ ដូច្នេះយើងគួរតែមានវិធីសំយោគរវាងការរីកចម្រើននៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា និងសមាហរណកម្មនៃស្មារតីសង្គម ដើម្បីឲ្យយើងអាចប្រើប្រាស់បានគ្រប់គ្នា។
- ក្រសួងកិច្ចការនារីមានការផ្សាយតាមកម្មវិធីវិទ្យុ ទាំងការបន្តផ្ទាល់ និងការថតចាក់ តាមវិទ្យុ ឬចុះផ្ទាល់ទៅតាមសហគមន៍ និងរៀបចំឲ្យមានជាវេទិកាសាធារណៈ អំពីបញ្ហាស្ត្រី
- គោលនយោបាយសម្រាប់ការអនុវត្ត គឺក្រសួងកិច្ចការនារីមានអនុវត្តតាមផែនការនារីរតនៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមនៅក្នុងការទប់ស្កាត់នូវអំពើហិង្សាក្នុងគ្រួសារ តាមរយៈចុះធ្វើការផ្សព្វផ្សាយច្បាប់
- ស្ត្រីដែលជាជនរងគ្រោះភាគច្រើនគឺមិនហ៊ាននិយាយចេញនោះទេ ពីព្រោះពួកគាត់ខ្លាចសង្គមមើលងាយ ដែលអាចនឹងធ្វើឲ្យស្ត្រីទាំងនោះបាត់បង់អនាគត ដែលនេះមិនត្រឹមតែប៉ះពាល់ដល់ជនរងគ្រោះប៉ុណ្ណោះទេ តែគឺជាការខាតបង់ដល់សង្គមទាំងមូលតែម្តង។
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី បានធ្វើការងារជាច្រើនទាក់ទងទៅនឹងការផ្សព្វផ្សាយនៃអនុសញ្ញាស៊ីដ។
- ក្រសួងកិច្ចការនារីបានផលិតជាប័ណ្ណព័ត៌មាន ដែលមានលេខទំនាក់ទំនាក់ និងបានចែកជូនប្រជាពលរដ្ឋបិទតាមលំនៅឋាន
- ជាគោលនយោបាយ ឬវិធានការក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី ក្រសួងកិច្ចការនារី និងអង្គការក្រៅរដ្ឋាភិបាលបានធ្វើកិច្ចសហការគ្នាមួយក្នុងការរៀបចំយុទ្ធនាការ១៦ថ្ងៃ។

អនុសាសន៍៖

- សូមឲ្យមានការស្រាវជ្រាវថ្នាក់ជាតិអំពីអំពើហិង្សាលើស្ត្រី
- រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលគួរធ្វើការរួមគ្នានៅក្នុងខ្លឹមសារ និងដែនការងារ (frame-work) តែមួយ ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី
- គួរតែមានវិធីសំយោគរវាងការរីកចម្រើននៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា និងសមាហរណកម្មនៃស្មារតីសង្គម ដើម្បីឲ្យយើងអាចប្រើប្រាស់បានគ្រប់គ្នា។
- សូមឲ្យព័ត៌មានដែលបានដាក់បង្ហោះលើបណ្តាញអ៊ីនធឺណិត ត្រូវមានអំណះអំណាង ឬប្រភព

យ៉ោងច្បាស់លាស់ ដើម្បីឲ្យឯកសារទាំងនោះអាចប្រើប្រាស់បានជាផ្លូវការ

- គួរតែមានការផ្សព្វផ្សាយនូវច្បាប់ស្តីអំពីការប្រើប្រាស់អំពីហិង្សាលើស្ត្រី ដែលត្រូវបានអនុម័ត ដើម្បីឲ្យប្រជាជនមានការយល់ដឹងបន្ថែម
- រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលគួរតែធ្វើការរួមគ្នា ដោយស្វែងរកយុទ្ធវិធីក្នុងការធ្វើការរួមគ្នាក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី។
- គួរតែមានការចាប់អារម្មណ៍ទៅលើការផ្សព្វផ្សាយច្បាប់ ដើម្បីឲ្យស្ត្រី ជាពិសេសស្ត្រីដែលនៅតាមទីជនបទមានការយល់ដឹង។

## *៥. កិច្ចពិភាក្សាស្តីអំពី «តម្រូវការបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី»*

### *សំណួរទី៧៖ តើរដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាល អាចធ្វើអ្វីខ្លះរួមគ្នា ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី?*

លោកស្រី ចាន់ សារ៉េត អ្នកសម្របសម្រួលកម្មវិធី នៃអង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ មានប្រសាសន៍ថា អង្គការលោកស្រីមានរៀបចំជាទិវាសិទ្ធិនារីអន្តរជាតិ៨មិនា និងមានផ្តល់ជាវគ្គបណ្តុះបណ្តាលដល់ស្ត្រី និងអាជ្ញាធរ និងផ្សព្វផ្សាយអំពីច្បាប់ស្តីពីការប្រឆាំងអំពើហិង្សាក្នុងគ្រួសារដល់ពួកគាត់។

លោកស្រី ប៊ី ឌីឡែន មន្ត្រីគម្រោង នៃអង្គការផេក-កម្ពុជា មានប្រសាសន៍ថា កន្លងមករដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលបានធ្វើកិច្ចសហការគ្នាក្នុងការបង្កើតឲ្យមានច្បាប់ស្តីពីការប្រឆាំងការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។ លោកស្រីបានបន្តថា រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលគួរបន្តធ្វើកិច្ចសហការគ្នាបន្តទៀត តាមរយៈធ្វើកិច្ចសហការជាមួយក្រសួងកិច្ចការនារី ពីព្រោះក្រសួងនេះមានតួនាទីយ៉ាងសំខាន់នៅក្នុងការងារទាក់ទងនឹងស្ត្រី និងមានអង្គការជាច្រើនដែលធ្វើការទាក់ទងនឹងការងារនេះ។ លោកស្រីបានផ្តល់ជាអនុសាសន៍ថា យើងគួរតែធ្វើការជាមួយនឹងក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយសារតែពួកគាត់គឺជាអ្នកដែលចុះផ្ទាល់ជាមួយនឹងប្រជាជន និងជាអ្នកដែលចុះប្រមូលទិន្នន័យពីប្រជាជន។



*លោកស្រី ពឹង យក់ហៀប*
*នាយិកាប្រតិបត្តិ នៃអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា*

លោកស្រី ពឹង យក់ហៀប នាយិកាប្រតិបត្តិនៃអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា មានប្រសាសន៍ថា អង្គការលោកស្រីមានគម្រោងកម្មវិធីមួយឈ្មោះថា យុត្តិធម៌ស្ត្រី ដោយមានសហការជាមួយក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ដោយមានមេធាវីការពារក្តីនៅកំពង់ឆ្នាំង កំពង់ស្ពឺ និងសៀមរាប។ ការលែងលះនៅមូលដ្ឋានត្រូវបានប្រគល់ឲ្យក្រុមប្រឹក្សាឃុំ-សង្កាត់ និងថ្នាក់ស្រុកជាអ្នកអនុវត្ត ក្រោមកិច្ចសហការជាមួយក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ក្នុងការសម្របសម្រួល។ ប្រសិនបើការសម្របសម្រួលនេះមិនបានទទួលជោគជ័យ ហើយបន្តទៅតុលាការ ខាងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជាមានមេធាវីសម្រាប់ទទួលការពារ។ ម៉្យាងវិញទៀត មន្ត្រីតាមថ្នាក់ស្រុក និងមន្ទីរមិនសូវជាមានចំណេះដឹងផ្នែកផ្លូវច្បាប់ ដូច្នេះតាមសំណូមពររបស់ពួកគាត់ អង្គការលោកស្រីបានផ្តល់ជាវគ្គបណ្តុះបណ្តាលជូនពួកគាត់បន្ថែមទៀត។

លោកស្រីបានបន្តថា លោកស្រីមានគំនិតមួយថា រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលគួររួមគ្នាលើគម្រោងកម្មវិធីមួយ ដើម្បីធ្វើការងារទាំងអស់គ្នា ដែលកន្លងមក យើងតែងតែធ្វើ ឬសរសេរគម្រោងដាច់ដោយឡែកពីគ្នា ដែលអាចធ្វើឲ្យមិនមានភាពជិតស្និតគ្នានៅក្នុងការអនុវត្តផងដែរ។ លោកស្រីបានកើតសរសើរចំពោះសកម្មភាពរបស់សមាគមសុខភាពប្រជាជន ដែលក្នុងនោះមិនមែនមានតែយុវជនទេ តែមានយុវនារីផងដែរ ដែលពួកគាត់បានចូលរួមក្នុងសកម្មភាពនេះ និងបានរៀនចេះពីវិធីការពារខ្លួនឯងបានទៀតផង។

លោកស្រីនាយិកានៃអង្គការវិទ្យាស្ថានបើកទូលាយមានប្រសាសន៍កោតសរសើរដល់សមាគមសុខភាពប្រជាជននិងយល់ស្របថា ក្នុងការលុបបំបាត់ ឬទប់ស្កាត់បញ្ហាអំពើហិង្សា ឬ ក៏បញ្ហាអ្វីក៏ដោយក៏ចាប់ផ្តើមពីខ្លួនយើងដែរ។ វាជាការសំខាន់ណាស់ដែលយើងបណ្តុះធនធានមនុស្សតាំងពីវ័យក្មេង ប្រកបដោយសុជីវធម៌ ថ្លៃថ្នូរ និងមានផ្នត់គំនិតល្អនៅក្នុងការរស់នៅ។ មនុស្សស្ថិតនៅក្នុងវ័យចំណាស់មានការលំបាកនៅក្នុងផ្លាស់ប្តូរឥរិយាបថរបស់គាត់។ លោកស្រីបានបន្តថា នៅក្នុងការរស់នៅក្នុងសង្គមខ្មែរបានបណ្តុះនូវការយល់ឃើញ និងឲ្យតម្លៃកូនប្រុសជាងកូនស្រីរួចទៅហើយ។ មានការស្រាវជ្រាវមួយបង្ហាញថា បុរសមានពេលទំនេរច្រើនជាងស្ត្រី ដោយសារនៅពេលទំនេរ ស្ត្រីគឺតែងតែជួយធ្វើការងារផ្ទះ។ ស្ត្រីត្រូវធ្វើការចំនួនពីរវេន មួយវេនគឺធ្វើការនៅការិយាល័យ និងមួយវេនទៀតធ្វើការនៅផ្ទះ ដែលការងារនេះមិនត្រូវបានគេផ្តល់តម្លៃនោះទេ។

លោក អ៊ូរ រតនៈ មានយោបល់ថា គម្រោងកម្មវិធីរបស់លោកមានកិច្ចសហការជាមួយក្រសួងកិច្ចការនារី និងក្រសួងអប់រំ យុវជន និងកីឡា។ លោកបានលើកឡើងនូវជីវិតផ្ទាល់ខ្លួនជូនដល់ប្រជុំថា កាលពីនៅរៀនវិទ្យាល័យ លោកតែងតែជួយធ្វើការជំនួសរបស់លោកធ្វើការងារផ្ទះបាយនៅពេលទំនេរ តែការធ្វើដូចនេះត្រូវបានជំទាស់យ៉ាងខ្លាំងពីឪពុករបស់លោក ដោយគាត់យល់ថាការងារនេះ ជាការងាររបស់ស្ត្រី បុរសមិនត្រូវធ្វើការងាររបៀបនេះទេ។ ក្នុងក្រុមគ្រួសាររបស់លោក កូនប្រុសត្រូវបានទទួលការយកចិត្តទុកដាក់ច្រើនជាងកូនស្រី សូម្បីតែការរៀបចំបន្ទប់គេង សម្ភារៈប្រើប្រាស់។ លោកបានបន្តថា នៅពេលលោកយាយរបស់លោកបានទទួលមរណភាព ទ្រព្យសម្បត្តិរបស់គាត់ភាគច្រើនគឺផ្តល់ដល់កូនប្រុស និងចៅប្រុស ចំណែកកូនស្រី និងចៅស្រីបានត្រឹមតែគ្រឿងអលង្ការមួយចំនួនប៉ុណ្ណោះ បើទោះបីជា កូនស្រី និងចៅស្រីគឺជាអ្នកមើលថែគាត់ក៏ដោយ។ នៅក្នុងវ័យនោះ លោកបានយល់ថា វាជារឿងធម្មតា។ លោកបានរកឃើញថា អ្វីដែលលោកបានជួបប្រទះនៅក្នុងគ្រួសារ គឺដូចជាអ្វីដែលកើតមាននៅក្នុងគ្រួសារ។ លោកបានចាប់ផ្តើមផ្លាស់ប្តូរទស្សនៈយល់ឃើញរបស់លោកនៅពេលដែលលោកចាប់ផ្តើមធ្វើការ និងចាប់ផ្តើមផ្លាស់ប្តូរការយល់ឃើញរបស់គ្រួសារលោក និងសាច់ញាតិរបស់លោក។ លោកបានលើកឡើងថា ពេលខ្លះ គឺមាការរើសអើងលើស្ត្រីតាំងពីនៅក្នុងពោះម្តាយមកម្ល៉េះ។

លោកស្រី លី ស៊ុនលីណា មន្ត្រីកម្មវិធី នៃអង្គការជំនួយរបស់វិហារដាណឺម៉ាក មានប្រសាសន៍ថា លោកស្រីមានភាពសប្បាយរីករាយណាស់ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំវេទិកាស្ត្រីនាពេលនេះ។ លោកស្រីបានលើកឡើងថា កាលពី១០-១៥ឆ្នាំមុន យើងបានធ្វើការដោយផ្អែកទៅលើ វិធីសាស្ត្រតម្រូវការជាក់ស្តែងជាមូលដ្ឋាន (Need Base Approach) ដោយមិនបានគិតពីវិធីសាស្ត្រសិទ្ធិជាមូលដ្ឋាន ឬយេនឌ័រជាមូលដ្ឋាន (Rights Base approach or Gender Base Approach)។ រហូតមកដល់ពេលឥឡូវនេះ បន្ទាប់ពីយើងបានអនុវត្តអស់រយៈពេល១០-១៥ឆ្នាំ យើងអាចសង្កេតឃើញថា តើអង្គការក្រៅរដ្ឋាភិបាលមានចំនួនប៉ុន្មាន? មានធនធានប៉ុន្មាន? មានកម្លាំង និងសមត្ថភាពប៉ុណ្ណាសម្រាប់ការធ្វើឲ្យសង្គមមានភាពផ្លាស់ប្តូរបាន? លោកស្រី


*លោកស្រី លី ស៊ុនលីណា មន្ត្រីកម្មវិធី នៃអង្គការជំនួយរបស់វិហារដាណឺម៉ាក*

បាបបន្តថា យើងមានទំហំតូចមែនទែន បើសិនជាប្រៀបធៀបជាមួយនឹងស្ថាប័នរបស់រដ្ឋាភិបាល។ តើអង្គការក្រៅរដ្ឋាភិបាលមានតួនាទីអ្វីខ្លះនៅក្នុងការសហការជាមួយនឹងស្ថាប័នរដ្ឋាភិបាលឲ្យមានប្រសិទ្ធភាពទៅលើធនធានដែលយើងមាន ក្នុងពេលដែលរដ្ឋាភិបាលគាត់មានអ្វីទាំងអស់ ដូចជា ទឹកដី ថវិកា ធនធានមនុស្ស និងអំណាច។ ដូច្នេះ យើងត្រូវពិនិត្យមើលឡើងវិញថាតើយើងនៅបន្តអនុវត្តវិធីសាស្ត្រតម្រូវការចាំបាច់ជាមូលដ្ឋាន ឬប្តូរជាវិធីសាស្ត្រសិទ្ធិជាមូលដ្ឋាន។ លោកស្រីបានបន្តថា វិធីសាស្ត្រតម្រូវការចាំបាច់ជាមូលដ្ឋាន គឺជាកាតព្វកិច្ចរបស់រដ្ឋាភិបាល ពីព្រោះគាត់កើតចេញពីប្រជាពលរដ្ឋ និងគាត់ត្រូវធានាថា ប្រជាពលរដ្ឋទទួលបានគ្រប់សិទ្ធិដែលពួកត្រូវទទួលបាន។ ដូច្នេះ យើងមិនអាចធ្វើការជំនួសរដ្ឋាភិបាលបានទេ។ លោកស្រីបានលើកឡើងថា នៅពេលប្រទេសជាតិមានការរីកចម្រើន លក្ខខណ្ឌផ្សេងៗទៀតមានការផ្លាស់ប្តូរ ដូច្នេះ វិធីសាស្ត្រតម្រូវការចាំបាច់ជាមូលដ្ឋានក៏មាននិន្នាការក្នុងការផ្លាស់ប្តូរ ពីវិធីសាស្ត្រតម្រូវការចាំបាច់ជាមូលដ្ឋានទៅជាវិធីសាស្ត្រសិទ្ធជាមូលដ្ឋាន ឬវិធីសាស្ត្រយេនឌ័រជាមូលដ្ឋាន ដោយយើងធ្វើយ៉ាងណាផ្តល់អំណាចដល់គាត់ ដើម្បីឲ្យពួកគាត់យល់ និងអាចធ្វើការទាមទារនូវសិទ្ធិដែលពួកគាត់គួរតែទទួលបាន។ លោកស្រីបានលើកឡើងអំពីរៀបចំកញ្ចប់ថវិការបស់រដ្ឋាភិបាលសម្រាប់ឆ្នាំ២០០៩ ដែលក្នុងនោះថវិកាភាគច្រើនបំផុតត្រូវបានចំណាយទៅលើក្រសួងការពារជាតិ និងចំណាយចំនួន ០.៥%ទៅលើក្រសួងកិច្ចការនារី ដូច្នេះយើងអាចឃើញអំពីអាទិភាពរបស់រដ្ឋាភិបាលយើង ដែលទាមទារឲ្យយើងធ្វើការដោយប្រើប្រាស់នូវវិធីសាស្ត្រសិទ្ធិជាមូលដ្ឋាន។ លោកស្រីបានលើកជាឧទាហរណ៍ថា កាលពីមុន យើងមានកម្មវិធីជីកអណ្តូងឲ្យប្រជាជន ប៉ុន្តែជុំវិញបញ្ហាសិទ្ធិក្នុងការទទួលបានទឹកស្អាតសម្រាប់បរិភោគគឺពួកគាត់បានដឹងទេ?។ លោកស្រីបានបន្តថា ចាប់តាំងពីពេលដែលពួកគាត់ចាប់កំណើត ពួកគាត់ទទួលបាននូវសិទ្ធិបួនធំៗរួចទៅហើយ ដូចជា៖ សិទ្ធិក្នុងការរស់រានមានជីវិត សិទ្ធិក្នុងការការពារ សិទ្ធិក្នុងការអភិវឌ្ឍន៍ និងសិទ្ធិក្នុងការចូលរួម។ ដូច្នេះ យើងមិនត្រឹមតែជីកអណ្តូងជូនគាត់ទេ តែយើងត្រូវធ្វើការពន្យល់គាត់ថាតើគាត់មានសិទ្ធអ្វីខ្លះដែលត្រូវទទួលបាន និងគាត់ត្រូវធ្វើយ៉ាងណា ទាមទារយ៉ាងណា ប្រសិនបើនាពេលអនាគត ភូមិរបស់គាត់គ្មានទឹកស្អាតសម្រាប់បរិភោគនោះ។ ជាសរុបមក លោកស្រីមានប្រសាសន៍ថា ដូច្នេះ យើងមិនអាចធ្វើការជំនួសរដ្ឋាភិបាលទេ តែយើងអាចចូលរួមសហការ និងធ្វើយ៉ាងណាដើម្បីឲ្យពួកគាត់មានការយល់ដឹងអំពីអំពីកាតព្វកិច្ចដែលគាត់ត្រូវបំពេញ។

លោកស្រីនាយិកានៃអង្គការវិទ្យាស្ថានបើកទូលាយមានប្រសាសន៍បានថ្លែងអំណរគុណលោកស្រីលីណា ដែលបានលើកឡើងអំពីចំណុចសំខាន់សម្រាប់កិច្ចពិភាក្សាអំពីតួនាទីរបស់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល។ លោកស្រីបានទទួលស្គាល់ថា កាលពីយើងទើបតែត្រូវបានរំដោះពីសង្គ្រាម ទាំងយើង ទាំងគេគឺមិនគិតពីអ្វីទេ សំខាន់គឺមានការហូបចុកឆ្អែត និងមិនមែនជាពេលដែលនិយាយអំពីសិទ្ធិមនុស្សនោះទេ និងគ្មានអ្នកណាយកចិត្តទុកដាក់ទេ។ នាពេលនោះ ទាំងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងក្រៅស្រុក បានប្រើវិធីសាស្ត្រតម្រូវការចាំបាច់ជាមូលដ្ឋាន។ ប៉ុន្តែ នាពេលបច្ចុប្បន្ន សង្គមមានការប្រែប្រួលច្រើន សេដ្ឋកិច្ចមានការវិវឌ្ឍន៍ និងតម្រូវការជាមូលដ្ឋានរបស់ពួកគាត់ត្រូវបានបំពេញ ដូច្នេះ ពួកគាត់ចាប់ផ្តើមនិយាយអំពីសិទ្ធិមនុស្ស។ លោកស្រីបានលើកឡើងថា ការទទួលបានសិទ្ធិរបស់ប្រជាពលរដ្ឋគឺនៅមានដែនកំណត់នៅឡើយ ដោយសារតែប្រទេសយើងជាប្រទេសដែលស្ថិតនៅក្រោមខ្សែបន្ទាត់ក្រីក្រនៅឡើយទេ។ ប្រជាជនយើងមានការយល់ថា គាត់ត្រូវគេវៃ ឬត្រូវគេយកដីគាត់ ទើបគាត់យល់ថានេះ គឺជាការរំលោភសិទ្ធ។ គាត់មិនបានយល់ថាគាត់ក្រ គាត់មិនមិនទឹកស្អាតសម្រាប់បរិភោគ ក៏មកពីគាត់មិនមានការយល់ដឹងក្នុងការប្រើប្រាស់សិទ្ធិរបស់

ខ្លួនដើម្បីទាមទារឲ្យរដ្ឋាភិបាលដោះស្រាយបញ្ហាទាំងនោះដល់គាត់ឡើយ។ លោកស្រីមានប្រសាសន៍ថា ការប្រើប្រាស់អំពើហិង្សា គឺជាអំពើខុសឆ្គងនិងជាបទឧក្រិដ្ឋ វាមិនមែនជាបញ្ហាធម្មតាដូចដែលពួកគាត់យល់ឃើញនោះទេ។ គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជាបានចែងថា នៅឆ្នាំ២០១៥ យើងនឹងធ្វើឲ្យមានការយល់ដឹងថា អំពើហិង្សាគឺជាបទឧក្រិដ្ឋ តែរហូតមកដល់ពេលនេះ យើងមិនទាន់ឃើញមានការស្រាវជ្រាវណាមួយបង្ហាញអំពីតួលេខនៃការយល់ដឹងរបស់ប្រជាជននេះនៅឡើយទេ។


*លោកស្រី ជា គីម អនុប្រធាននាយកដ្ឋានបណ្ណាល័យ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

លោកស្រី ជា គីម អនុប្រធាននាយកដ្ឋានបណ្ណាល័យ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានប្រសាសន៍ថា រដ្ឋាភិបាលបានបង្កើតនូវច្បាប់ជាច្រើន និងត្រូវបានអនុម័តឲ្យប្រើប្រាស់ ព្រមទាំងត្រូវបានយកច្បាប់ទាំងនោះទៅផ្សព្វផ្សាយដល់ប្រជាជនផងដែរ ដូចជា ច្បាប់ស្តីពីការទប់ស្កាត់ការប្រើអំពើហិង្សា និងកិច្ចការពារជនរងគ្រោះជាដើម។ លោកស្រីបានបន្តថា ថ្មីៗនេះរដ្ឋសភា/ព្រឹទ្ធសភាបានរៀបចំឲ្យមានវេទិកាផ្លាស់ប្តូរយោបល់ស្តីពីការវិភាគថវិកាឆ្នាំ២០០៩ផ្តោតទៅលើបញ្ហាយេនឌ័រពីសំណាក់តំណាងអង្គការស្ត្រី។ លោកស្រីបានបន្តថា ការជួយកាត់បន្ថយអំពើហិង្សានៅក្នុងគ្រួសារមួយបានជួយសម្រួលជាច្រើនដូចជា ជួយឲ្យពួកគាត់រស់នៅប្រកបដោយភាពសុខុមរមនា ធ្វើឲ្យចំណូលក្នុងគ្រួសារមានការកើនឡើង ដោយសារស្ត្រីអាចចេញទៅជួយរកចំណូលបានបន្ថែមក្រោយពេលដែលគាត់ទទួលបានការបណ្តុះបណ្តាលជំនាញ។ លោកស្រីបានបន្តថា ទាំងរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា មាន កិច្ចខិតខំប្រឹងប្រែងជាច្រើន ដោយក្នុងនោះមានកិច្ចសហការពីសំណាក់អង្គការក្រៅរដ្ឋាភិបាលជាច្រើន ជុំវិញបញ្ហាកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា។

***សំណួរទី៨ និងទី៩៖ -តើរដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាល អាចធ្វើអ្វីខ្លះរួមគ្នា ដើម្បីសម្រេចបានគោលដៅ អភិវឌ្ឍសហស្សវត្សអំពីសមភាពយេនឌ័រ? តើរដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាល មានយុទ្ធសាស្ត្រយ៉ាងណា ក្នុងការប្រើប្រាស់ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី?***

លោកស្រីនាយិកានៃអង្គការវិទ្យាស្ថានបើកទូលាយមានប្រសាសន៍ថា កម្មវិធីស្ត្រី នៃអង្គការវិទ្យាស្ថានបើកទូលាយបានធ្វើមូលដ្ឋានីយកម្មលើទម្រង់នៃ **«ការនិយាយថា ទេ ចំពោះអំពើហិង្សាលើស្ត្រី»** ដើម្បីចូលរួមនៅក្នុងយុទ្ធនាការពិភពលោក ក្រោមកិច្ចសហការជាមួយអង្គការយូនីហ្វេម ប្រចាំទីក្រុងញ៉ូវយក អង្គការយូនីហ្វេម ប្រចាំតំបន់អាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ អង្គការយូនីហ្វេម ប្រចាំប្រទេសកម្ពុជា។ ទម្រង់នេះត្រូវបានដាក់លើវិបផតថលស្តីអំពីស្ត្រី http://women.open.org.kh សម្រាប់អញ្ជើញអ្នកអានវិបផតថលស្តីអំពីស្ត្រីផ្តល់ហត្ថលេខា ដើម្បីបង្ហាញអំពីការគាំទ្ររបស់ពួកគាត់ក្នុងការប្រឆាំងនឹងការប្រើប្រាស់អំពើហិង្សាលើស្ត្រី។ លោកស្រីបានបន្តថា ក្នុងការប្រមូលហត្ថលេខា កម្មវិធីស្ត្រីបានសហការជាមួយនឹងសមាគមសុខភាពប្រជាជន ហើយហត្ថលេខាទាំងនោះត្រូវបានផ្ញើទៅកាន់អង្គការយូនីហ្វេម ប្រចាំទីក្រុងញ៉ូវយក ដើម្បីផ្ញើជូនលោក បាន គី មូន អគ្គលេខាធិការ អង្គការសហប្រជាជាតិ ដើម្បីគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់លោក ក្នុងទិវាពិភពលោកស្តីការប្រឆាំងអំពើហិង្សាលើស្ត្រី នាថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០០៨។ លោកស្រីបានបន្តថា វិបផតថលស្តីអំពីស្ត្រីមានដាក់នូវឯកសារទាក់ទងនឹងសិទ្ធិ និងច្បាប់ សម្រាប់អ្នកអានគ្រប់រូប មិនមែនសម្រាប់តែស្ត្រីនោះទេ ដើម្បី

ឲ្យពួកគាត់មានការយល់ដឹងអំពីសិទ្ធិរបស់មនុស្ស។ លោកស្រីបានបន្តថា បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានការរីកចម្រើន តែស្ត្រីនៅតំបន់អាស៊ីអាគ្នេយ៍មានចំនួនតិចដែរអាចប្រើប្រាស់វាបាន ដែលធ្វើឲ្យស្ត្រីឃ្លាតឆ្ងាយពីការអភិវឌ្ឍន៍សង្គម និងពិភពលោក ដែលធ្វើឲ្យពួកគាត់បាត់បង់នូវឱកាសនៃការអភិវឌ្ឍន៍ខ្លួនឯង និងការអភិវឌ្ឍន៍នៃពិភពលោក។

លោកស្រី ពឹង យក់ហៀប មានប្រសាសន៍សរសើរចំពោះនិស្សិតស្ត្រីដែលប្រើប្រាស់អ៊ីនធឺណិតនៅតាមហាងអ៊ីនធឺណិត ដែលប្រហែលជាគ្មានភាសាខ្មែរទេ។ លោកស្រីបានផ្តល់ជាអនុសាសន៍ថា សូមឲ្យអង្គការវិទ្យាស្ថានបើកទូលាយសហការជាមួយហាងអ៊ីនធឺណិតនៅទីក្រុងភ្នំពេញ និងនៅតាមបណ្តាខេត្ត និងក្រុង និងសូមឲ្យមានកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើយ៉ាងណាឲ្យសិស្សនិស្សិតមានជំនាញនៅក្នុងការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា។


*ទិដ្ឋភាព នៃកិច្ចប្រជុំវេទិកាស្ត្រី*

លោកស្រីនាយិកានៃអង្គការវិទ្យាស្ថានបើកទូលាយ មានប្រសាសន៍ថា អង្គការវិទ្យាស្ថានបើកទូលាយ បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងកម្មវិធីមួយឈ្មោះថា កម្មវិធីសាលារៀនបើកចំហ ដែលក្នុងនោះអង្គការវិទ្យាស្ថានបើកទូលាយបានផ្តល់ជាវគ្គបណ្តុះបណ្តាលកម្មវិធីកុំព្យូទ័រជាភាសាខ្មែរ ដល់គរុសិស្សទូទាំងប្រទេស ដែលក្នុងនោះមានស៊ីឌីកម្មវិធី និងសៀវភៅសិក្សាសម្រាប់ចែកជូនផងដែរ។ អង្គការវិទ្យាស្ថានបើកទូលាយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដោយបញ្ចូលឲ្យមានការសិក្សាអំពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យានៅក្នុងការអប់រំ។ ដូច្នេះ ចាប់ពីឆ្នាំសិក្សានេះទៅសិស្សដែលសិក្សាចាប់ពីថ្នាក់ទី១០ គឺមានកម្មវិធីសិក្សាអំពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ជាភាសាខ្មែរនេះហើយ។ លោកស្រីបានបន្ថែមថា កម្មវិធីស្ត្រីនៃអង្គការវិទ្យាស្ថានបើកទូលាយបានធ្វើកិច្ចសហការជាមួយនឹងហាងអ៊ីនធឺណិតមួយចំនួន ដែលក្នុងនោះយើងបានដំឡើងកម្មវិធីកុំព្យូទ័រជាភាសាខ្មែរដល់ពួកគាត់ និងបានបិទផ្សាយនូវព័ត៌មានអំពីវិបផតថលស្តីអំពីស្ត្រីផងដែរ។ លោកស្រីបានបន្តថា តែអ្វីដែលជាឧបសគ្គនោះ គឺនៅតាមស្ថាប័ន និងអង្គការក្រៅរដ្ឋាភិបាល និងឯកជននៅប្រើប្រាស់ពុម្ពអក្សរលីមូន ឬពុម្ពអក្សរផ្សេងៗទៀតជាច្រើន ហើយពុម្ពអក្សរទាំងអស់នោះមិនអាចអានគ្នាបានទេ ដូច្នេះហើយបានជាយើងបង្កើតឲ្យមានពុម្ពអក្សរជារួមមួយ។ លោកស្រីបានបន្តថា មូលហេតុដែលយើងបង្កើតវិបផតថលជាភាសាខ្មែរ គឺដោយសារតែ ឯកសារច្បាប់ សិទ្ធិ និងឯកសារដ៏ទៃទៀត ភាគច្រើនគឺជាភាសាខ្មែរ និងយោងតាមការស្រាវជ្រាវមុនពេលបង្កើតគម្រោងបង្ហាញថា ក្នុងចំណោមអង្គការស្ត្រីដែលមានចំនួន២៨ មានតែ៨អង្គការទេដែលមានវិបសាយ ក្នុងនោះ៦ជាវិបសាយភាសាអង់គ្លេស និង២វិបសាយជាភាសាខ្មែរ ដែលមានព័ត៌មានភាគច្រើនជាប្រវត្តិរបស់អង្គភាព។ ចំពោះអង្គការដែលធ្វើការងារទាក់ទងនឹងសិទ្ធិមនុស្ស មានតែ៩អង្គការទេដែលមានវិបសាយ និងជាភាសាអង់គ្លេស។ លោកស្រីបានលើកឡើងថា តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ចូលរួមក្នុងការលុបបំបាត់អំពើហិង្សាលើស្ត្រី យើងឃើញថា មានហត្ថលេខាគាំទ្រប្រហែលជាង៥០០០ ក្នុងយុទ្ធនាការនៃ «**ការនិយាយថា ទេ ចំពោះអំពើហិង្សាលើស្ត្រី**»។ តាមរយៈការប្រើប្រាស់បញ្ជីសំបុត្ររួម ដែលជាផ្នែកមួយនៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា គឺអាចឲ្យយើងអាចប្រើប្រាស់វាសម្រាប់ការចែករំលែក និងផ្សព្វផ្សាយ

ព័ត៌មាន និងការពិភាក្សាជុំវិញបញ្ហាអំពើហិង្សាលើស្ត្រី។

លោកស្រី លី ស៊ុនលីណា មានប្រសាសន៍កោតសរសើរដល់អង្គការវិទ្យាស្ថានបើកទូលាយដែលមានគំនិតផ្តួចផ្តើមក្នុងការបង្កើតឲ្យមានវិបផតថលជាភាសាខ្មែរ។ លោកស្រីបានបន្តថា លោកស្រីបានទទួលនូវអ៊ីមែលឆ្លើយឆ្លងគ្នាជាច្រើនតាមរយៈបញ្ជីសំបុត្ររួម gender@lists.open.org.kh។

លោក ធាវ ប៊ុន្នី មន្ត្រីបច្ចេកទេស នៃអង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ មានយោបល់ថា បច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា មិនមែនសំដៅតែទៅលើ អ៊ីនធឺណិតនោះទេ តែវាសំដៅទៅលើទូរទស្សន៍ វិទ្យុ ឬក៏តាមទូរស័ព្ទជាដើម។ លោកបានបន្តថា តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាជាមធ្យោបាយសម្រាប់ធ្វើការផ្សព្វផ្សាយ ធ្វើឲ្យស្ត្រីបានដឹងអំពីបញ្ហាដែលបានកើតមាន និងដឹងថាតើគាត់ត្រូវធ្វើយ៉ាងម៉េចនៅពេលមានបញ្ហាកើតឡើង ដែលធ្វើឲ្យពួកគាត់អាចដោះស្រាយបញ្ហាបានប្រសើរជាងមុន។

## VI. លទ្ធផលនៃកិច្ចពិភាក្សា

កិច្ចប្រជុំវេទិកាស្ត្រីបានរកឃើញថា៖

- កម្លាំងស្ត្រីចូលរួមនៅក្នុងកម្លាំងពលកម្មមានចំនួនជាង ៧០% នៃកម្លាំងពលកម្មសរុប ដូច្នេះប្រសិនយើងព្រងើយកន្តើយ រើសអើងមនុស្សស្ត្រី ឬមានផ្នត់គំនិតយេនឌ័រ (Gender Stereotype) មានន័យថា យើងបានកាត់ចេញនូវកម្លាំងពលកម្មជាងពាក់កណ្តាល សម្រាប់ការអភិវឌ្ឍន៍ប្រទេស និងធ្វើឲ្យគ្មានសមភាពយេនឌ័រ
- តាមការស្រាវជ្រាវបានបង្ហាញថា និស្សិតស្ត្រី និងស្ត្រីដែលជាអ្នកបម្រើសេវាកម្មកម្សាន្ត មានសិទ្ធិតិចតួចបំផុតក្នុងការចរចា និងធ្វើសេចក្តីសម្រេចចិត្ត
- វប្បធម៌របស់សង្គមកម្ពុជាបានធ្វើឲ្យមានភាពលំអៀង ដូចជា ចាប់តាំងពីចាប់កំណើត កូនប្រុសត្រូវបានចាត់ទុកដូចជាគ្រាប់ពេជ្រ និងអ្វីដែលគាត់ធ្វើគឺត្រូវទាំងអស់
- វាជាការសំខាន់ណាស់ដែលយើងបណ្តុះធនធានមនុស្សតាំងពីវ័យក្មេង ប្រកបដោយសុជីវធម៌ថ្លៃថ្នូរ និងមានផ្នត់គំនិតល្អនៅក្នុងការរស់នៅ។ មនុស្សស្ថិតនៅក្នុងវ័យចំណាស់មានការលំបាកនៅក្នុងផ្លាស់ប្តូរឥរិយាបថរបស់គាត់
- អំពើហិង្សាភាគច្រើន គឺកើតឡើងពីបុរស និងពីភាពជាបុរស
- ករណីលែងលះនៅមូលដ្ឋានត្រូវបានប្រគល់ឲ្យក្រុមប្រឹក្សាឃុំ-សង្កាត់ និងថ្នាក់ស្រុកជាអ្នកអនុវត្តតែមន្ត្រីតាមថ្នាក់ស្រុក និងមន្ទីរមិនសូវជាមានចំណេះដឹងផ្នែកផ្លូវច្បាប់
- គួរតែធ្វើការជាមួយនឹងក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយសារតែពួកគាត់ គឺជាអ្នកដែលចុះផ្ទាល់ជាមួយនឹងប្រជាជន និងជាអ្នកដែលចុះប្រមូលទិន្នន័យពីប្រជាជន
- បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាមានការរីកចម្រើន តែស្ត្រីនៅតំបន់អាស៊ីអាគ្នេយ៍មានចំនួនតិចដែរអាចប្រើប្រាស់វាបាន ដែលធ្វើឲ្យស្ត្រីឃ្លាតឆ្ងាយពីកន្លែងប្រមូលផ្តុំចំណេះដឹងពិភពលោក (pool of global knowledge) ដែលធ្វើឲ្យពួកគាត់បាត់បង់នូវឱកាសនៃការអភិវឌ្ឍន៍ខ្លួនឯង និងការអភិវឌ្ឍន៍សង្គម
- ក្នុងចំណោមអង្គការស្ត្រីដែលមានចំនួន២៨ មានតែ៨អង្គការទេដែលមានវិបសាយ ក្នុងនោះ៦ជាវិបសាយភាសាអង់គ្លេស និង ២វិបសាយជាភាសាខ្មែរ ដែលមានព័ត៌មានភាគច្រើនជាប្រវត្តិរបស់អង្គភាព។ ចំពោះអង្គការដែលធ្វើការងារទាក់ទងនឹងសិទ្ធិមនុស្ស មានតែ៩អង្គការទេដែលមាន

វិបសាយ និងជាភាសាអង់គ្លេស។

- តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាជាមធ្យោបាយសម្រាប់ធ្វើការផ្សព្វផ្សាយ ធ្វើឲ្យស្ត្រីបានដឹងអំពីបញ្ហាដែលបានកើតមាន និងដឹងថាតើគាត់ត្រូវធ្វើយ៉ាងម៉េចនៅពេលមានបញ្ហាកើតឡើង ដែលធ្វើឲ្យពួកគាត់អាចដោះស្រាយបញ្ហាបានប្រសើរជាងមុន
- កន្លងមករដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលបានធ្វើកិច្ចសហការគ្នាជាច្រើន ដូចជាក្នុងការបង្កើតឲ្យមានច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ការចូលរួមនៅក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងអំពើហិង្សានៅតាមមូលដ្ឋាន
- រដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា មានកិច្ចខិតខំប្រឹងប្រែងជាច្រើន ដោយក្នុងនោះមានកិច្ចសហការពីសំណាក់អង្គការក្រៅរដ្ឋាភិបាលជាច្រើន ជុំវិញបញ្ហាកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា
- រដ្ឋសភា/ព្រឹទ្ធសភាបានរៀបចំឲ្យមានវេទិកាផ្លាស់ប្តូរយោបល់ស្តីពីការវិភាគថវិកាឆ្នាំ២០០៩ផ្តោតទៅលើបញ្ហាយេនឌ័រពីសំណាក់តំណាងអង្គការស្ត្រី។
- គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជាបានចែងថា នៅឆ្នាំ២០១៥ យើងនឹងធ្វើឲ្យមានការយល់ដឹងថា អំពើហិង្សាគឺជាបទឧក្រិដ្ឋ តែរហូតមកដល់ពេលនេះ យើងមិនទាន់ឃើញមានការស្រាវជ្រាវណាមួយបង្ហាញអំពីតួលេខនៃការយល់ដឹងរបស់ប្រជាជននេះនៅឡើយទេ។
- ពេលប្រទេសជាតិមានការរីកចម្រើន លក្ខខណ្ឌផ្សេងៗទៀតមានការផ្លាស់ប្តូរ ដូច្នេះវិធីសាស្ត្រតម្រូវការចាំបាច់ជាមូលដ្ឋាន(Need Base Approach) ក៏មាននិន្នាការក្នុងការផ្លាស់ប្តូរ ពីវិធីសាស្ត្រតម្រូវការចាំបាច់ជាមូលដ្ឋាន ទៅជាវិធីសាស្ត្រសិទ្ធិជាមូលដ្ឋាន ឬវិធីសាស្ត្រយេនឌ័រជាមូលដ្ឋាន (Rights Base approach or Gender Base Approach)ដោយយើងធ្វើយ៉ាងណាផ្តល់អំណាចដល់គាត់ ដើម្បីឲ្យពួកគាត់យល់ និងអាចធ្វើការទាមទារនូវសិទ្ធិដែលពួកគាត់គួរតែទទួលបាន។
- អង្គការមិនមែនរដ្ឋាភិបាលមិនអាចធ្វើការជំនួសរដ្ឋាភិបាលទេ តែយើងអាចចូលរួមសហការ និងធ្វើយ៉ាងណាដើម្បីឲ្យរដ្ឋាភិបាលមានការយល់ដឹងអំពីកាតព្វកិច្ចដែលពួកគាត់ត្រូវបំពេញ។

**អនុសាសន៍៖**

- រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលគួរបន្តធ្វើកិច្ចសហការគ្នាបន្តទៀត តាមរយៈធ្វើកិច្ចសហការជាមួយក្រសួងកិច្ចការនារី ពីព្រោះក្រសួងនេះមានតួនាទីយ៉ាងសំខាន់នៅក្នុងការងារទាក់ទងនឹងស្ត្រី និងមានអង្គការជាច្រើនដែលធ្វើទាក់ទងនឹងការងារនេះ។

- រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលគួររួមគ្នាធ្វើការលើគម្រោងកម្មវិធីមួយ

## VII. សេចក្តីបញ្ចប់

កិច្ចពិភាក្សាវេទិកាស្ត្រី បានបញ្ចប់ដោយទទួលនូវលទ្ធផលល្អ ស្តីអំពី **«តម្រូវការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យាក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី»** ។ កិច្ចប្រជុំបានដំណើរការយ៉ាងល្អ ដោយមានការចូលរួមចែករំលែកនូវមតិយោបល់ និងបទពិសោធន៍របស់លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញាជាអ្នកចូលរួម។ លោកស្រី ជឹម ម៉ាណាវី បានមានមតិថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ការចូលរួម និងការចំណាយពេលវេលារបស់តំណាងស្ថាប័នទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំវេទិកាស្ត្រីនេះ ។

**អ្នកធ្វើរបាយការណ៍៖**

កញ្ញា ប្រាក់ សុខាយុ អ្នកសម្របសម្រួលកម្មវិធីស្ត្រី

**ពិនិត្យ និងកែសម្រួលដោយ៖**

លោកស្រី ជឹម ម៉ាណាវី នាយិកាប្រតិបត្តិ

**ជំនួយការទូទៅ៖**

លោក ជឹម លីនណា មន្ត្រីទំនាក់ទំនង នៃកម្មវិធីស្ត្រី

កញ្ញា កៅ ពៅលក្ខិណា អ្នកវិភាគព័ត៌មាន នៃកម្មវិធីស្ត្រី

**រូបភាព និងបច្ចេកទេស៖**

លោក ហ៊ី ចាន់ហាន អ្នកគ្រប់គ្រងតំបន់បណ្តាញ

លោក ម៉ក់ តារា ជំនួយការបច្ចេកទេសព័ត៌មានវិទ្យា